**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**
**លេខ** :..........៤៤៩..............ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្ដីពី
# ការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្ដីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងលិខិតលេខ ៤៣៣៧ សហវ-អឧហ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីអត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទាន សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាព អនុវត្តចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពជូនដល់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ។

**ប្រការ ៣.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- ***ភាគទាន*** សំដៅដល់ប្រាក់ដែលនិយោជកត្រូវបង់តាមច្បាប់ទុកជាមូលនិធិសម្រាប់ការផ្តល់តាវកាលិក
- ***ឧត្តរជីវី*** សំដៅដល់អ្នកនៅរស់មានជីវិតជាប្រពន្ធ ឬប្តី និងកូននៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិក ប.ស.ស ក្រោយពីទទួលមរណៈភាពដោយហានិភ័យការងារ។
- ***ធនលាភ*** សំដៅដល់ប្រាក់ឧបត្ថម្ភដល់ជនបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយសារហានិភ័យការងារចាប់ពី ២០% ឡើងទៅ។

## ជំពូកទី២

## អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទាន

### ផ្នែកទី១

### អត្រាភាគទាន

**ប្រការ ៤.-**

អត្រាភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ត្រូវបានកំណត់ស្មើនឹង ០,៨ (សូន្យក្បៀសប្រាំបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត មុនកាត់ពន្ធ ។

អត្រាភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ត្រូវបានកំណត់ស្មើនឹង ២,៦ (ពីរក្បៀសប្រាំមួយ) ភាគរយ នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត មុនកាត់ពន្ធ ។

ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត ត្រូវបានកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

ចំពោះអត្រាភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់សមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ និង ឧត្តរជីវី ជាបន្ទុករបស់ ប.ស.ស ត្រូវបានកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ នៃប្រាក់ធនលាភ ។

## ផ្នែកទី២
## បែបបទ និងនីតិវិធីនៃការបង់ភាគទាន

**ប្រការ ៥.-**

កាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទានដំបូង ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដែល ប.ស.ស បានចេញវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ។ ការប្រគល់វិញ្ញាបនបត្រនេះត្រូវមានបញ្ជាក់កាលបរិច្ឆេទ ដែលសហគ្រាស គ្រឹះស្ថានបានទទួលពីប.ស.ស ។

ការចាប់ផ្តើមបង់ភាគទានដំបូងសម្រាប់ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិការួចហើយ ត្រូវកំណត់ដោយ ប.ស.ស ។

និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន ត្រូវបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពក្នុងពេលដំណាលគ្នាសម្រាប់ខែនីមួយៗ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ ។

**ប្រការ ៦.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងប្រការ៥ខាងលើ ត្រូវបង់បន្ថែមនូវការប្រាក់ប្រចាំខែ តាមអត្រា ១,៥ ( មួយក្បៀសប្រាំ ) ភាគរយ នៃចំនួនភាគទានជាក់ស្តែង ដែលត្រូវបង់ក្នុងខែនីមួយៗ និងត្រូវទទួលការពិន័យជាប្រាក់ ដូចមានចែងក្នុងមាត្រា ៣៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស ប្រាក់ឈ្នួលប្រចាំខែត្រូវគិតជាប្រាក់រៀល តាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា ដែលជូនដំណឹងដោយ ប.ស.ស ។

**ប្រការ ៧.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

- បង់ផ្ទាល់នៅធនាគារដែលបានកំណត់ ។ ការបង់ភាគទានរបៀបនេះ និយោជកត្រូវអនុវត្តតាមទម្រង់ "បែបបទបង់ភាគទាន" ឬទម្រង់ "២.០១" ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។
- បង់តាមរយៈសេវាកម្មអ៊ីនធឺណែតប៊ែងឃីង ឬសេវាកម្មយូនីធី ការចំណាយលើសេវាកម្មនេះគឺជាបន្ទុករបស់និយោជក ។
- បង់តាមរយៈសេវាកម្មដទៃផ្សេងទៀត តាមការណែនាំរបស់បេឡាជាតិរបបសន្តិសុខសង្គម ។

បង្កាន់ដៃបង់ភាគទាននៅធនាគារ របាយការណ៍ចំនួនកម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច) លិខិតប្រកាសបង់ភាគទាន លិខិតបញ្ជាក់ចំនួនកម្មករនិយោជិត តារាងបើកប្រាក់ឈ្នួល ឬឯកសារចាំបាច់ផ្សេងៗ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យប.ស.ស ឬផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវចេញលិខិតបញ្ជាក់ការបង់ភាគទាន បន្ទាប់ពីបានទទួល "បង្កាន់ដៃបង់ភាគទាន" (ចំពោះការបង់ភាគទានផ្ទាល់នៅធនាគារ) ឬបន្ទាប់ពីមានការបញ្ជាក់នៅក្នុងរបាយការណ៍ធនាគារ អំពីការបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន (ចំពោះការបង់ភាគទានតាមរយៈសេវាកម្មអ៊ីនធឺណែតប៊ែងឃីង ឬសេវាកម្មយូនីធី ឬសេវាកម្មផ្សេងទៀត) ។

**ប្រការ ៨.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ ឬតារាងបើកប្រាក់ឈ្នួលតាមខែនីមួយៗ បញ្ជីឈ្មោះកម្មករនិយោជិត និងឯកសារពាក់ព័ន្ធផ្សេងៗជូន ប.ស.ស ដើម្បីត្រួតពិនិត្យនៅពេលចាំបាច់ ។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**ប្រការ ៩.-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ ១០.-**

ប្រកាសលេខ ១០៨ ក.ប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ប្រកាសលេខ ២៩៤ ក.ប/ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ១០៨ ក.ប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទ នៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ប្រកាសលេខ ២២០ ក.ប/ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់អត្រាភាគទាន និង បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ......២៤៩............... កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

# តារាងភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព

| ថ្នាក់ | ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន (គិតជារៀល) | ភាគទានប្រចាំខែផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត ១នាក់ (០,៨%) | ភាគទានប្រចាំខែផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ១នាក់ (២,៦%) | ភាគទានសរុប |
|---|---|---|---|---|---|
| ១ | ក្រោម ២០០.០០០ | ២០០.០០០ | ១.៦០០ | ៥.២០០ | ៦.៨០០ |
| ២ | ២០០.០០១- ២៥០.០០០ | ២២៥.០០០ | ១.៨០០ | ៥.៨៥០ | ៧.៦៥០ |
| ៣ | ២៥០.០០១ -៣០០.០០០ | ២៧៥.០០០ | ២.២០០ | ៧.១៥០ | ៩.៣៥០ |
| ៤ | ៣០០.០០១ -៣៥០.០០០ | ៣២៥.០០០ | ២.៦០០ | ៨.៤៥០ | ១១.០៥០ |
| ៥ | ៣៥០.០០១ -៤០០.០០០ | ៣៧៥.០០០ | ៣.០០០ | ៩.៧៥០ | ១២.៧៥០ |
| ៦ | ៤០០.០០១ -៤៥០.០០០ | ៤២៥.០០០ | ៣.៤០០ | ១១.០៥០ | ១៤.៤៥០ |
| ៧ | ៤៥០.០០១ -៥០០.០០០ | ៤៧៥.០០០ | ៣.៨០០ | ១២.៣៥០ | ១៦.១៥០ |
| ៨ | ៥០០.០០១ -៥៥០.០០០ | ៥២៥.០០០ | ៤.២០០ | ១៣.៦៥០ | ១៧.៨៥០ |
| ៩ | ៥៥០.០០១ -៦០០.០០០ | ៥៧៥.០០០ | ៤.៦០០ | ១៤.៩៥០ | ១៩.៥៥០ |
| ១០ | ៦០០.០០១ -៦៥០.០០០ | ៦២៥.០០០ | ៥.០០០ | ១៦.២៥០ | ២១.២៥០ |
| ១១ | ៦៥០.០០១ -៧០០.០០០ | ៦៧៥.០០០ | ៥.៤០០ | ១៧.៥៥០ | ២២.៩៥០ |
| ១២ | ៧០០.០០១ -៧៥០.០០០ | ៧២៥.០០០ | ៥.៨០០ | ១៨.៨៥០ | ២៤.៦៥០ |
| ១៣ | ៧៥០.០០១ -៨០០.០០០ | ៧៧៥.០០០ | ៦.២០០ | ២០.១៥០ | ២៦.៣៥០ |
| ១៤ | ៨០០.០០១ -៨៥០.០០០ | ៨២៥.០០០ | ៦.៦០០ | ២១.៤៥០ | ២៨.០៥០ |
| ១៥ | ៨៥០.០០១ -៩០០.០០០ | ៨៧៥.០០០ | ៧.០០០ | ២២.៧៥០ | ២៩.៧៥០ |
| ១៦ | ៩០០.០០១ -៩៥០.០០០ | ៩២៥.០០០ | ៧.៤០០ | ២៤.០៥០ | ៣១.៤៥០ |
| ១៧ | ៩៥០.០០១ -១.០០០.០០០ | ៩៧៥.០០០ | ៧.៨០០ | ២៥.៣៥០ | ៣៣.១៥០ |
| ១៨ | ១.០០០.០០១ -១.០៥០.០០០ | ១.០២៥.០០០ | ៨.២០០ | ២៦.៦៥០ | ៣៤.៨៥០ |
| ១៩ | ១.០៥០.០០១ -១.១០០.០០០ | ១.០៧៥.០០០ | ៨.៦០០ | ២៧.៩៥០ | ៣៦.៥៥០ |
| ២០ | ១.១០០.០០១ -១.១៥០.០០០ | ១.១២៥.០០០ | ៩.០០០ | ២៩.២៥០ | ៣៨.២៥០ |
| ២១ | ១.១៥០.០០១ -១.២០០.០០០ | ១.១៧៥.០០០ | ៩.៤០០ | ៣០.៥៥០ | ៣៩.៩៥០ |
| ២២ | ១.២០០.០០១ ឡើង | ១.២០០.០០០ | ៩.៦០០ | ៣១.២០០ | ៤០.៨០០ |

ឧបសម្ព័ន្ធ២ប្រកាសលេខ ២២៩ កប/ប្រ.កស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

**២.០១**

**សម្រាប់មន្ត្រីប.ស.ស**
លេខកូដភាគទាន:
ហត្ថលេខា: .......................... / /

# បែបបទបង់ភាគទាន

១.ឈ្មោះសហគ្រាស:........................................................................................................ ២.លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន: | | | | | | | | |

៣.ឈ្មោះសហគ្រាសជាអក្សរឡាតាំង:..................................................................................................................................

| ភាគទានបង់សម្រាប់ខែ..........ឆ្នាំ........... | | | | | | | |
|---|---|---|---|---|---|---|---|
| លេខរៀង | លេខអត្តសញ្ញាណកម្មករនិយោជិត | ឈ្មោះកម្មករនិយោជិត | ប្រាក់ឈ្នួលប្រចាំខែ | ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន | ភាគទានផ្នែកហានិភ័យការងារ | ភាគទានផ្នែកថែទាំសុខភាព | ភាគទានសរុប |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | សរុប= | | | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលផ្តល់ជូនខាងលើពិតជាត្រឹមត្រូវ និងធានាខុសត្រូវលើរាល់កំហុសឆ្គងទាំងអស់។

.......................... ថ្ងៃទី ខែ ឆ្នាំ

**ហត្ថលេខា និងត្រានិយោជក**

ឧបសម្ព័ន្ធ៣ប្រកាសលេខ៤៤៩..កប/ប្រ.កស្តីពីការកំណត់អត្រាភាគទាននិងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

២.០២

**សម្រាប់មន្ត្រីប.ស.ស**
លេខកូដភាគទាន:
ហត្ថលេខា: .......................... / /

# បែបបទបង់ភាគទានបង្គ្រប់

១.ឈ្មោះសហគ្រាស:............................................................ ២.លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន: | | | | | | | | |

៣.ឈ្មោះសហគ្រាសជាអក្សរឡាតាំង:............................................................

ភាគទានបង់បង្គ្រប់សម្រាប់ខែ..........ឆ្នាំ...........

| លេខរៀង | លេខអត្តសញ្ញាណកម្មករនិយោជិត | ឈ្មោះកម្មករនិយោជិត | ប្រាក់ឈ្នួលប្រចាំខែ | ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន | ភាគទានផ្នែកហានិភ័យការងារ | ភាគទានផ្នែកថែទាំសុខភាព | ភាគទានសរុប |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | សរុប= | | | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលផ្តល់ជូនខាងលើពិតជាត្រឹមត្រូវ និងធានាខុសត្រូវលើរាល់កំហុសឆ្គងទាំងអស់។

.......................... ថ្ងៃទី ខែ ឆ្នាំ

**ហត្ថលេខា និងត្រានិយោជក**